# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ៧៧០ អនក្រ.បក

## អនុក្រឹត្យ
### ស្តីពី
### ការបំពេញបន្ថែមខ្លឹមសារក្នុង
### អនុក្រឹត្យលេខ ៨៨ ចុះថ្ងៃទី ០៥ ខែកញ្ញា ឆ្នាំ ២០០១
### ស្តីពីគោលការណ៍សមាហរណកម្មមន្ត្រីរាជការស៊ីវិលទៅក្នុងក្របខ័ណ្ឌថ្មី

## រាជរដ្ឋាភិបាលកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញ នៃ ព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃ ព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦ នស/៩៤ ចុះថ្ងៃទី ២៦ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/០១២៩៧ / ២៧៣ ចុះថ្ងៃទី ០១ ខែ ធ្នូ ឆ្នាំ ១៩៩៧ ស្តីពីគោលការណ៍រួម នៃការរៀបចំមុខងារសាធារណៈ
- បានឃើញព្រះរាជក្រឹត្យលេខ នស / រកត / ០៤០០/ ០៧៥ ចុះថ្ងៃទី ២២ ខែ មេសា ឆ្នាំ ២០០០ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីក្រមការ ក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រឹត្យលេខ នស / រកត / ០៥០០/ ០៩៧ ចុះថ្ងៃទី ១៩ ខែ ឧសភា ឆ្នាំ ២០០០ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌអនុរក្សពន្ធនាគារ ក្រសួងមហាផ្ទៃ
- បានឃើញអនុក្រឹត្យលេខ ៨៨ អនក្រ.បក ចុះថ្ងៃទី ០៥ ខែ កញ្ញា ឆ្នាំ ២០០១ ស្តីពីគោលការណ៍សមាហរណកម្មមន្ត្រីរាជការស៊ីវិលទៅក្នុងក្របខ័ណ្ឌថ្មី
- បានឃើញអនុក្រឹត្យលេខ ៣៦៧ អនក្រ.តត ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ២០០០ ស្តីពីការកាត់ក្របខ័ណ្ឌនគរបាលជាតិអោយទៅបំរើការងារក្នុងក្របខ័ណ្ឌរដ្ឋបាលស៊ីវិលក្រសួងមហាផ្ទៃ
- តាមសំណើរបស់សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សំរេច

**មាត្រា ១ :** ត្រូវបានបំពេញបន្ថែមខ្លឹមសារក្នុងអនុក្រឹត្យ លេខ ៨៨ អនក្រ . បក ចុះថ្ងៃទី ០៥ ខែ កញ្ញា

www.pheakdeylaw.com

ឆ្នាំ ២០០១ ស្តីពីគោលការណ៍សមាហរណកម្មមន្ត្រីរាជការស៊ីវិលទៅក្នុងក្របខ័ណ្ឌថ្មី ចំពោះមន្ត្រីរាជការរដ្ឋបាលស៊ីវិលនៃក្រសួងមហាផ្ទៃដែលកំពុងកាន់មុខតំណែងនៅនាយកដ្ឋានពន្ធនាគារ ពន្ធនាគារកណ្តាល និងពន្ធនាគារខេត្តក្រុង ៖

**ក្នុងមាត្រា ៤ ចំពូកទី ២ ៖**

ក / <u>ឋានន្តរស័ក្តិនាយក្រមការ</u>

- ប្រធានពន្ធនាគារកណ្តាល

ខ / <u>ឋានន្តរស័ក្តិក្រមការដើមខ្សែ</u>

- ប្រធានពន្ធនាគារខេត្ត ក្រុង
- អនុប្រធានពន្ធនាគារកណ្តាល

គ / <u>ឋានន្តរស័ក្តិក្រមការ</u>

- អនុប្រធានពន្ធនាគារខេត្ត ក្រុង
- នាយផ្នែកថ្នាក់កណ្តាល
- នាយផ្នែកពន្ធនាគារកណ្តាល

ឃ / <u>ឋានន្តរស័ក្តិនាយអនុរក្ស</u>

- អនុប្រធានផ្នែកថ្នាក់កណ្តាល
- អនុប្រធានផ្នែកពន្ធនាគារកណ្តាល
- ប្រធានផ្នែកពន្ធនាគារខេត្ត ក្រុង

ង / <u>ឋានន្តរស័ក្តិអនុរក្សដើមខ្សែ</u>

- អនុប្រធានផ្នែកពន្ធនាគារខេត្ត ក្រុង
- ប្រធានក្រុមពន្ធនាគារកណ្តាល

**ក្នុងមាត្រា ៥ ចំពូកទី ២ ៖**

ការផ្ទេរបញ្ចូលទៅក្នុងថ្នាក់នៃឋានន្តរស័ក្តិនីមួយ ៗ របស់ក្របខ័ណ្ឌអនុរក្សពន្ធនាគារ ដែលមានមុខតំណែង ត្រូវគិតតាមចំនួនឆ្នាំបំរើការងាររដ្ឋ ដូចមានកំណត់ក្នុងតារាងឧបសម្ព័ន្ធ ទី ១ នៃ អនុក្រឹត្យនេះ ។

**ក្នុងមាត្រា ១៥ ចំពូកទី ៤ ៖**

ចំពោះមន្ត្រីដែលពុំមានមុខតំណែងក្នុងរចនាសម្ព័ន្ធ ត្រូវផ្ទេរបញ្ចូលទៅក្នុងក្របខ័ណ្ឌអនុរក្សពន្ធនាគារក្រសួងមហាផ្ទៃ ដូចមានកំណត់ក្នុងតារាងឧបសម្ព័ន្ធទី២ នៃអនុក្រឹត្យនេះ ។

<u>**មាត្រា ២**</u> ៖ រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការ នៃក្រសួង ស្ថាប័ន



www.pheakdeylaw.com

ដែលពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀង ៗ ខ្លួន ។

**មាត្រា ៣ :** អនុក្រឹត្យនេះចូលជាធរមាន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

*រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ កក្កដា ឆ្នាំ ២០០២*

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល :**

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា ២*
- *ឯកសារ - កាលប្បវត្តិ*

www.pheakdeylaw.com

ឧបសម្ព័ន្ធទី ១ នៃ អនុក្រឹត្យលេខ ៧០ អនក្រ.បក ចុះថ្ងៃទី ២៣ ខែ កក្កដា ឆ្នាំ ២០០២

## គោលការណ៍សមាហរណកម្មមន្ត្រីរដ្ឋបាលបច្ចុប្បន្ន
## ចូលក្នុងក្របខ័ណ្ឌអនុរក្សពន្ធនាគារ

**<u>មុខតំណែងដែលត្រូវផ្ទេរបញ្ចូលទៅក្នុងឋានន្តរស័ក្តិនាយអនុរក្សមាន :</u>**

- អនុប្រធានផ្នែកថ្នាក់កណ្តាល
- អនុប្រធានផ្នែកពន្ធនាគារកណ្តាល
- ប្រធានផ្នែកពន្ធនាគារខេត្ត ក្រុង

| ឋានន្តរស័ក្តិនាយអនុរក្ស | អតីតភាពបំរើការងាររដ្ឋ |
| --- | --- |
| ថ្នាក់លេខ ១ | |
| ថ្នាក់លេខ ២ | |
| ថ្នាក់លេខ ៣ | ២៥ ឆ្នាំ ឡើង |
| ថ្នាក់លេខ ៤ | ២២ - ២៥ ឆ្នាំ |
| ថ្នាក់លេខ ៥ | ១៩ - ២២ ឆ្នាំ |
| ថ្នាក់លេខ ៦ | ក្រោម - ១៩ ឆ្នាំ |

**<u>មុខតំណែងដែលត្រូវផ្ទេរបញ្ចូលទៅក្នុងឋានន្តរស័ក្តិអនុរក្សជើងខ្សែមាន :</u>**

- អនុប្រធានផ្នែកពន្ធនាគារខេត្ត ក្រុង
- ប្រធានក្រុមពន្ធនាគារកណ្តាល

| ឋានន្តរស័ក្តិអនុរក្សជើងខ្សែ | អតីតភាពបំរើការងាររដ្ឋ |
| --- | --- |
| ថ្នាក់លេខ ១ | |
| ថ្នាក់លេខ ២ | |
| ថ្នាក់លេខ ៣ | |
| ថ្នាក់លេខ ៤ | |
| ថ្នាក់លេខ ៥ | ២៣ ឆ្នាំ ឡើង |
| ថ្នាក់លេខ ៦ | ២០ - ២៣ ឆ្នាំ |
| ថ្នាក់លេខ ៧ | ១៧ - ២០ ឆ្នាំ |
| ថ្នាក់លេខ ៨ | ១៤ - ១៧ ឆ្នាំ |
| ថ្នាក់លេខ ៩ | ១១ - ១៤ ឆ្នាំ |
| ថ្នាក់លេខ ១០ | ក្រោម - ១១ ឆ្នាំ |

T005

www.pheakdeylaw.com

## ឧបសម្ព័ន្ធទី ២ នៃ អនុក្រឹត្យលេខ៧០ អនក្រ.បក ចុះថ្ងៃទី ២៣ ខែកក្កដា ឆ្នាំ ២០០២

## គោលការណ៍សមាហរណកម្មទៅតាមបៀវត្សចូលក្នុងក្របខ័ណ្ឌអនុរក្សពន្ធនាគារ

| ឋានន្តរស័ក្តិ និង ថ្នាក់ | បៀវត្សមូលដ្ឋានបច្ចុប្បន្ន (១) | ផ្សេងៗ |
|---|---|---|
| **ឋានន្តរស័ក្តិទី ១ នាយអនុរក្ស** | | |
| ថ្នាក់លេខ ១ | | |
| ថ្នាក់លេខ ២ | | |
| ថ្នាក់លេខ ៣ | | |
| ថ្នាក់លេខ ៤ | | |
| ថ្នាក់លេខ ៥ | 44400 - 44500 | |
| ថ្នាក់លេខ ៦ | 40400 | |
| **ឋានន្តរស័ក្តិទី ២ អនុរក្សដើមខ្សែ** | | |
| ថ្នាក់លេខ ១ | | |
| ថ្នាក់លេខ ២ | | |
| ថ្នាក់លេខ ៣ | | |
| ថ្នាក់លេខ ៤ | | |
| ថ្នាក់លេខ ៥ | | |
| ថ្នាក់លេខ ៦ | | |
| ថ្នាក់លេខ ៧ | 38500 | |
| ថ្នាក់លេខ ៨ | 36400 | |
| ថ្នាក់លេខ ៩ | 35500 | |
| ថ្នាក់លេខ ១០ | 32400 | |
| **ឋានន្តរស័ក្តិទី ៣ អនុរក្ស** | | |
| ថ្នាក់លេខ ១ | | |
| ថ្នាក់លេខ ២ | | |
| ថ្នាក់លេខ ៣ | | |
| ថ្នាក់លេខ ៤ | | |
| ថ្នាក់លេខ ៥ | | |
| ថ្នាក់លេខ ៦ | | |
| ថ្នាក់លេខ ៧ | | |
| ថ្នាក់លេខ ៨ | | |
| ថ្នាក់លេខ ៩ | | |
| ថ្នាក់លេខ ១០ | 28400 | |
| ថ្នាក់លេខ ១១ | 26400 - 27400 | |
| ថ្នាក់លេខ ១២ | 24400 - 25400 | |
| ថ្នាក់លេខ ១៣ | 22400 - 23400 | |
| ថ្នាក់លេខ ១៤ | 20400 - 21400 | |

***កំណត់សំគាល់*** : (១) មិនគិតប្រាក់វិភាជន៍គ្រួសារ ប្រាក់ឧបត្ថម្ភតំបន់ និង ជំនាញ

www.pheakdeylaw.com